Economics Today
Cambodia's Business Magazine

# ប្រកាសព័ត៌មាន

EIC វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា

## ផ.ស.សប្រទេសកម្ពុជា ត្រូវបានព្យាករថាកើន ៨,៧ ភាគរយ នៅ ឆ្នាំ២០១១ ៖ វ.ស.ក

រាជធានីភ្នំពេញ, ២១ កក្កដា ២០១១ ៖ ក្រោយពីងើបឡើងយ៉ាងមាំទាំ នៅឆ្នាំ២០១០រួចមក ផលិតផលក្នុងស្រុកសរុប(ផ.ស.ស) របស់ប្រទេសកម្ពុជា ត្រូវបានព្យាករថាកើន ៨,៧ ភាគរយ នៅឆ្នាំ២០១១ ។ សន្ទុះកំណើននៃអនុវិស័យវាយនភណ្ឌនិងសម្លៀកបំពាក់ ជ្រោងពីក្រោយការកើនឡើងនៃផ.ស.សនេះ នេះបើយោងតាមរបាយការណ៍ពិសេសរបស់ «វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា(វ.ស.ក)» ដែលសហការបោះពុម្ពផ្សាយពីរដងក្នុងមួយឆ្នាំ ជាមួយទស្សនាវដ្ដី «សេដ្ឋកិច្ចថ្ងៃនេះ» ។

ដោយប្រើប្រាស់ម៉ូដែលសេដ្ឋកិច្ចរបស់ខ្លួន ការព្យាកររបស់វ.ស.ក សម្រាប់កំណើនឆ្នាំ២០១១ មានលក្ខណៈសុទិដ្ឋិនិយម ជាងព្យាករណ៍របស់បណ្ដាស្ថាប័នពាក់ព័ន្ធផ្សេងទៀត មកទល់បច្ចុប្បន្ននេះ ។ ខណៈដែលរាជរដ្ឋាភិបាលកម្ពុជា(រ.រ.ក) រំពឹងអត្រាកំណើន ៦,០ ភាគរយ ធ/ធ នៅឆ្នាំ២០១១ ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដែលរួមមាន ធនាគារអភិវឌ្ឍន៍អាស៊ី(ធ.អ.អ) មូលនិធិរូបិយវត្ថុអន្តរជាតិ(ម.រ.អ) និងធនាគារពិភពលោក(ធ.ព) ទាំងអស់ព្យាករថា សេដ្ឋកិច្ចកម្ពុជានឹងធំធាត់ ក្នុងអត្រា ៦,៥ ភាគរយ ។

**ព្យាករណ៍ ផ.ស.ស របស់កម្ពុជា ដោយស្ថាប័នពាក់ព័ន្ធ (% ឆ្នូរ, ធ/ធ)**

| ស្ថាប័ន | ២០១០ប | ២០១០ព | ២០១០ព |
|---|---|---|---|
| វ.ស.ក | ៦,៥ | ៨,៧ | ៦,៦ |
| រ.រ.ក | ៥,៩ | ៦,០ | ៦,៥ |
| ធ.អ.អ | ៦,៣ | ៦,៥ | ៦,៨ |
| ម.រ.អ | ៦,០ | ៦,៥ | ៦,៥ |
| ធ.ព | ៦,៧ | ៦,៥ | ៦,៥ |

**ប្រភព** ៖ វ.ស.ក ៖ វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា, ស្រង់ពីម៉ូដែលរបស់វ.ស.ក ។ រ.រ.ក ៖ រាជរដ្ឋាភិបាលកម្ពុជា, ទាញចេញពីវេទិកាសាយរបស់ស.ហ.វ នៅថ្ងៃ២៩ មិថុនា ២០១១ ។ ធ.អ.អ ៖ ធនាគារអភិវឌ្ឍន៍អាស៊ី, "Asian Development Outlook", ២០១១ ។ ម.រ.អ ៖ មូលនិធិរូបិយវត្ថុអន្តរជាតិ, "World Economic Outlook", មេសា ២០១១ ។ ធ.ព ៖ ធនាគារពិភពលោក, "East Asia and Pacific Economic Update", មីនា ២០១១ ។ ប = បាន់ស្មាន, ព = ព្យាករណ៍, ធ/ធ = ឆ្នាំធៀបឆ្នាំ ។

ផ្អែកតាមវ.ស.ក អនុវិស័យវាយនភណ្ឌនិងសម្លៀកបំពាក់ ដែលរាប់បញ្ចូលផលិតកម្មសម្លៀកបំពាក់ ស្បែកជើង និងវាយនភណ្ឌផ្សេងទៀត ដើរតួជាចលករដ៏សំខាន់ អូសទាញកំណើនសេដ្ឋកិច្ចជាតិ ។

"យើងព្យាករថា អនុវិស័យវាយនភណ្ឌនិងសម្លៀកបំពាក់ នឹងសម្រេចបានកំណើនពិត ២១,១ ភាគរយ នៅឆ្នាំ២០១១ ដែលនេះនឹងផ្ដល់វិភាគទានដ៏ច្រើន ដល់កំណើនផ.ស.សរបស់កម្ពុជា ។" នេះបើតាមប្រសាសន៍របស់លោក ឃិន ពិសី ដែលជាអ្នកស្រាវជ្រាវផ្នែកសេដ្ឋកិច្ចនៃវ.ស.ក និងជាអ្នកនិពន្ធមួយរូបក្នុងចំណោមអ្នកនិពន្ធចម្បងៗនៃរបាយការណ៍ពិសេសនេះ ។

លោកបានបន្ថែមទៀតថា ៖ "ទឹកប្រាក់ពីការនាំចេញផលិតផលវាយនភណ្ឌនិងសម្លៀកបំពាក់ អំឡុងបួនខែដើមឆ្នាំនេះ មានចំនួនច្រើនជាងឆ្នាំមុនយ៉ាងខ្លាំង ។ នេះជាមូលដ្ឋានរឹងមាំមួយ សម្រាប់កំណើនការនាំចេញសរុប នាដំណាច់ឆ្នាំនេះ ។ ជាងនេះទៀតនោះ យើងពុំឃើញមានសញ្ញាណនៃការធ្លាក់ចុះការនាំចេញណាមួយនោះឡើយ សម្រាប់បណ្ដាខែខាងមុខ" ។

**ការនាំចេញផលិតផលវាយនភណ្ឌ និងការនាំចូលសាច់ក្រណាត់របស់កម្ពុជា**




**ប្រភព** ៖ វ.ស.ក, ស្រង់យកពីគយ

តួលេខពីគយបានបង្ហាញថា ទឹកប្រាក់ពីការនាំចេញផលិតផលវាយនភណ្ឌនិងសម្លៀកបំពាក់ បានហក់ឡើង ៤៤ ភាគរយ ធ/ធ អំឡុងបួនខែដើមឆ្នាំនេះ ។

រីឯនិន្នាការនៃទឹកប្រាក់ពីការនាំចេញ បូកបង្គរ ១២ ខែ ចុងក្រោយ បាននិងកំពុងកើនឡើងខ្ពស់ផងដែរ តាំងពីចុងឆ្នាំ២០០៩មក ដែលធ្វើឲ្យឈានដល់ជាង ៣,៣ ពាន់លានដុល្លារ គិតត្រឹមខែមេសា ឆ្នាំ២០១១ ។ បើតាមការពន្យល់របស់លោក ឃិន ពិសី និន្នាការនេះ ហាក់មិនធ្លាក់ចុះឡើយ នៅក្នុងបណ្ដាប៉ុន្មានខែខាងមុខ ។

ការកើនឡើងនៃបរិមាណនាំចូលសាច់ក្រណាត់ គឺជាសូចនាករដោយឡែកមួយទៀត ដែលបញ្ជាក់បន្ថែមអំពីកំណើននៃការនាំចេញផលិតផលវាយនភណ្ឌនិងសម្លៀកបំពាក់នេះ ។

លោក ឃិន ពិសី ពន្យល់ថា ៖ "បណ្ដារោងចក្រកាត់ដេរជាច្រើន ត្រូវនាំចូលវត្ថុធាតុដើមជាមុន យ៉ាងហោចណាស់ពីពីរទៅបីខែ ដើម្បីជានាឆ្លើយតបទាន់ពេលវេលា ទៅនឹងការបញ្ជាទិញរបស់អតិថិជន ។ ហេតុនេះ ការកើនឡើងនៃការនាំចូលសាច់ក្រណាត់ ជាសញ្ញាណនៃកំណើនបរិមាណនាំចេញ ទៅថ្ងៃមុខ" ។

បរិមាណនាំចូលសាច់ក្រណាត់ បូកបង្គរ ១២ ខែ ចុងក្រោយ បាននិងកំពុងឡើងខ្ពស់ ហើយកើន ២៦ ភាគរយ ឆ/ឆ គិតត្រឹមខែមេសាឆ្នាំ២០១១ ។




វិស័យឧស្សាហកម្ម ដែលវ.ស.កព្យាករថាលូតឡើង ១៥,៨ ភាគរយ នឹងត្រូវបានជំរុញដោយកំណើនផលិតកម្ម និងវិនិយោគ ក្នុងបណ្ដាអនុវិស័យផលិតកម្មចំណីអាហារ(ជាពិសេសខាងកិនស្រូវ) និងផលិតកម្មជ័រកៅស៊ូ ។

ចំណែកឯវិស័យកសិកម្មវិញ អត្រាកំណើនត្រូវបានព្យាករថានឹងមាន ៤,១ ភាគរយ នៅ២០១១ ពេលប្រហាក់ប្រហែលនឹងកំណើនឆ្នាំមុន ។ បន្ទាប់ពីទទួលបានកំណើនខ្ពស់ អស់ប៉ុន្មានឆ្នាំរួចមក ផលិតកម្មស្រូវ និងដំណាំផ្សេងទៀត ត្រូវបានរំពឹងថានឹងថមថយកំណើន នារយៈពេលមធ្យមខាងមុខ ដោយសារតែលទ្ធភាពផលិតកម្មហាក់ឈានដល់ដែនកំណត់របស់វា ។

វិស័យសេវាកម្ម ត្រូវបានព្យាករថាលូតលាស់ ៦,៩ ភាគរយ នាឆ្នាំនេះ ។ ការកើនឡើងវិញនៃចំនួនមកដល់របស់ទេសចរបូករួមនឹងដំណើរការប្រសើរនៃអនុវិស័យហិរញ្ញវត្ថុ ព្រមជាមួយនឹងកំណើននៃអនុវិស័យដឹកជញ្ជូននិងទំនាក់ទំនង បានបង្កលក្ខណៈល្អ ដល់ការលូតលាស់នៃវិស័យសេវាកម្មនេះ ។

សម្រាប់ឆ្នាំនេះ បណ្ដាអនុវិស័យមួយចំនួនផ្សេងទៀត ដែលរួមមាន នេសាទ សំណង់ និងជំនួញអចលនទ្រព្យ នឹងនៅតែទទួលបានកំណើនដ៏ស្ដួចស្ដើង រៀងគ្នា ០,៧ ភាគរយ ១,៩ ភាគរយ និង ១,៣ ភាគរយ ។

### *អំពី វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ៖*

*វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា គឺជាស្ថាប័នស្រាវជ្រាវសេដ្ឋកិច្ចឯករាជ្យ ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៣ ។ ការងារជំនាញរបស់វិទ្យាស្ថាននេះ រួមមាន ៖ ការវិភាគម៉ាក្រូសេដ្ឋកិច្ច, ការធ្វើម៉ូដែលព្យាករណ៍សេដ្ឋកិច្ច, ការប្រមូលព័ត៌មានសម្រាប់ជាលក្ខដ្ឋានដើមទីនៃការសិក្សា(baseline survey) និងការសិក្សាទីផ្សារ, និងការអភិវឌ្ឍមុខជំនួញ(business development) ។*

### *អំពី «ឃ្លាំមើលសេដ្ឋកិច្ចកម្ពុជា» ៖*

*របាយការណ៍ស្រាវជ្រាវ «ឃ្លាំមើលសេដ្ឋកិច្ចកម្ពុជា» បាននិងកំពុងចេញផ្សាយដោយវ.ស.ក តាំងពីឆ្នាំ២០០៤មកម្ល៉េះ ។ នេះក៏ដោយសារកិច្ចគាំទ្រដ៏ប្រសើរ របស់ធនាគារពិភពលោក ដែលមានរហូតដល់ឆ្នាំ២០០៩ ។ ចាប់ពីពេលនោះមក វ.ស.កបន្តចេញផ្សាយ«ឃ្លាំមើលសេដ្ឋកិច្ចកម្ពុជា»នេះ ដោយសហការជាមួយទស្សនាវដ្ដី «សេដ្ឋកិច្ចថ្ងៃនេះ» ។ អ្នកនិពន្ធ «ឃ្លាំមើលសេដ្ឋកិច្ចកម្ពុជា» ៖ លោក នៅ សីហា (អ្នកស្រាវជ្រាវជាន់ខ្ពស់ និងអ្នកគ្រប់គ្រងការស្រាវជ្រាវ) និងលោក ឃិន ពិសី (អ្នកស្រាវជ្រាវ) ។*

សម្រាប់ចម្ងល់ និងការណាត់សម្ភាសន៍ជាមួយអ្នកនិពន្ធ សូមទាក់ទងយើងខ្ញុំ តាមរយៈអ៊ីម៉ែល ៖ etm@etmcambodia.com ឬលេខទូរស័ព្ទ ៖ ០២៣-៩៨៧-៩៤៣ ។